# បរាភវសូត្រ (សេចក្តីវិនាស ១២ យ៉ាង)

## (ដកពីបិដក និង អដ្ឋកថា)



ដកស្រង់រៀបរៀងដោយភិក្ខុ ឆួន សារ៉េត ព.ស២៥៦៦, គ.ស២០២៣

# សេចក្តីផ្តើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បានរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និងបដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជានិស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹងឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះ នឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្តីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្តីសុខ សេចក្តីចម្រើន និង រួចចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្តីសុខ សេចក្តីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី០៦ ខែ*មេសា*ឆ្នាំ២០២៣

ភិក្ខុសារត្ថធម្មោ នួន សារ៉េត

## បរាភវសូត្រ ទី៦ (បិដក ៥៤ ទំព័រ ៣៦)

[១០] ខ្ញុំបានស្តាប់មកយ៉ាងនេះ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គ្រានោះឯង ទេវតា ១ អង្គ កាលដែលរាត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនជុំវិញទាំងអស់ ឲ្យភ្លឺស្វាងហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយស្ថិតក្នុងទីសមគួរ។ លុះទេវតានោះ ស្ថិតនៅក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដោយគាថាដូច្នេះថា។

**បរាភវន្តំ បុរិសំ** **មយំ បុច្ឆាម គោតមំ**
**ភវន្តំ បុដ្ឋុមាគម្ម** **កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយមកសូមទូលសួរ នូវហេតុដែលគួរចម្រើនវិនាស
ប្រុសស្រីក្នុងលោកសន្និវាស ដែលនឹងវិនាសសាបសូន្យចាកគុណ ។
ឆ្ពោះព្រះគោតមព្រះអង្គមានបុណ្យ មេត្តានិមន្តសម្តែងឲ្យទាន
ធម្មជាតិដូចម្តេចដែលជាប្រធាន នាំសត្វឲ្យមានសេចក្តីវិនាស ។

**សុវិជានោ ភវំ ហោតិ** **សុវិជានោ បរាភវោ**
**ធម្មកាមោ ភវំ ហោតិ** **ធម្មទេស្សី បរាភវោ ។**

អ្នកដែលចម្រើនតថាគតស្គាល់ងាយ អ្នកដែលអន្តរាយតថាគតស្គាល់ពិត
អ្នកប្រាថ្នាធម៌ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្តនឹងបានចម្រើន
អ្នកដែលទ្រុស្តធម៌ស្អប់ធម៌ឥតកើន ឥតកើនចម្រើនវិនាសទៅមុខ ។

**ឥតិហេតំ វិជានាម** **បឋមោ សោ បរាភវោ**
**ទុតិយំ ភគវា ព្រូហិ** **កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
ក្តីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឯងព្រោះហេតុដូច្នោះ
វិនាសនោះឈ្មោះទីមួយទាន់ហន់ ។

**អសន្តស្ស បិយា ហោន្តិ**
**សន្តេន កុរុតេ បិយំ**
**អសតំ ធម្មំ រោចេតិ**
**តំ បរាភវតោ មុខំ ។**

អ្នកដែលស្រឡាញ់ពេញចិត្តស្នេហា
តែងមិនស្រឡាញ់ពេញចិត្តទាំងអស់
តែនឹងមនុស្សណាអសប្បុរស
នឹងអ្នកសប្បុរសមកធ្វើជាមិត្រ ។

**ឥតិហេតំ វិជានាម**
**ទុតិយោ សោ បរាភវោ**
**តតិយំ ភគវា ព្រូហិ**
**កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
ក្តីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឯងព្រោះហេតុដូច្នោះ
វិនាសនោះឈ្មោះទីពីរទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត
វិនាសទីបីអ្វីជាប្រធាន
សូមទ្រង់និមន្តសម្តែងឲ្យទាន
នាំសត្វឲ្យមានសេចក្តីវិនាស ។

**និទ្ទាសីលី សភាសីលី**
**អនុដ្ឋាតា ច យោ នរោ**
**អលសោ កោធបញ្ញាណោ**
**តំ បរាភវតោ មុខំ ។**

អ្នកដេកច្រើនមួយនិយាយច្រើនមួយ
អ្នកខ្ជិលច្រអូសមិនមានខ្នះខ្នែង
និងអ្នកឥតព្យួយឥតគិតប្រឹងប្រែង
ខឹងច្រើនសម្តែងឲ្យគេឃើញបាន ។

ហេតុធម៌ទាំងនោះមិនជាកល្យាណ
មានជាប្រធានតិចច្រើនដោយហោច
នាំឲ្យខកខានខូចប្រយោជន៍
នាំបង់ប្រយោជន៍ហើយឲ្យវិនាស ។

**ឥតិហេតំ វិជានាម**
**តតិយោ សោ បរាភវោ**

**ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទីបីទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្ដែងឲ្យទាន
វិនាសទីបួនអ្វីជាប្រធាន នាំសត្វឲ្យមានសេចក្ដីវិនាស ។

**យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ**

**បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។**

នរជនណាមានទ្រព្យធនធាន ហើយខ្លួនមិនបានចិញ្ចឹមរក្សា
មាតាបិតាដែលចាស់ជរា ហេតុនោះទៅជានាំឲ្យវិនាស ។

**ឥតិហេតំ វិជានាម ចតុត្ថោ សោ បរាភវោ**

**បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្ដីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទីបួនទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្ដែងឲ្យទាន
វិនាសទីប្រាំអ្វីជាប្រធាន នាំសត្វឲ្យមានសេចក្ដីវិនាស ។

**យោ ព្រាហ្មណំ វា សមណំ វា អញ្ញំ វាបិ វនិព្វកំ**

**មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។**

ជនបញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ ពួកស្មូមឬអ្នកដទៃៗ
ដោយមុសាវាទឃ្លាតពាក្យប្រពៃ នោះប្រធាននៃសេចក្ដីវិនាស ។

**ឥតិហេតំ វិជានាម　　បញ្ចមោ សោ បរាភវោ**

**ឆដ្ឋមំ ភគវា ព្រូហិ　　កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង　　វិនាសនោះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនេះបើរាប់សង្គ្រោះ　　វិនាសនោះឈ្មោះទីប្រាំទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត　　សូមទ្រង់និមន្តសម្តែងឲ្យទាន

វិនាសទីប្រាំមួយអ្វីជាប្រធាន　　នាំសត្វឲ្យមានសេចក្តីវិនាស ។

**បហុតវិត្តោ បុរិសោ　　សហិរញ្ញោ សភោជនោ**

**ឯកោ ភុញ្ជតិ សាទូនិ　　តំ បរាភវតោ មុខំ ។**

បុរសអ្នកមានទ្រព្យធនធានច្រើន　　មាសប្រាក់ចម្រើននិងគ្រឿងអាហារ

លបលាក់របស់ដែលឆ្ងាញ់ពិសា　　ស៊ីម្នាក់ឯងជាប្រធានវិនាស ។

**ឥតិហេតំ វិជានាម　　ឆដ្ឋមោ សោ បរាភវោ**

**សត្តមំ ភគវា ព្រូហិ　　កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង　　វិនាសនេះឯងព្រោះហេតុដូច្នោះ

ក្តីវិនាសនេះបើរាប់សង្គ្រោះ　　វិនាសនេះឈ្មោះទីប្រាំមួយទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត　　សូមទ្រង់និមន្តសម្តែងឲ្យទាន

វិនាសទីប្រាំពីរអ្វីជាប្រធាន　　នាំសត្វឲ្យមានសេចក្តីវិនាស ។

**ជាតិត្ថទ្ធោ ធនត្ថទ្ធោ　　គោត្តត្ថទ្ធោ ច យោ នរោ**

**សញ្ញាតឹ អតិមញ្ញេតិ　　តំ បរាភវតោ មុខំ ។**

អ្នកដែលប្រកាន់ជាតិទ្រព្យត្រកូល　　ហើយមិនប្រមូលសាច់ញាតិសន្តាន

មើលងាយញាតិខ្លួនដោយអាងខ្លួនមាន នេះជាប្រធានសេចក្ដីវិនាស ។

**ឥតិហេតំ វិជ្ជានាម សត្តមោ សោ បរាភវោ**

**អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង វិនាសនោះឯងព្រោះហេតុដូច្នោះ

ក្ដីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទីប្រាំពីរទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្ដែងឲ្យទាន

វិនាសទីប្រាំបីអ្វីជាប្រធាន នាំសត្វឲ្យមានសេចក្ដីវិនាស ។

**ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ**

**លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។**

ជនអ្នកប្រព្រឹត្តល្បែងបីប្រការ ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ទាំងឡាយ

ធ្វើទ្រព្យខ្លួនមានឲ្យអន្តរាយ ការល្បែងទាំងឡាយនោះនាំវិនាស ។

**ឥតិហេតំ វិជានាម អដ្ឋមោ សោ បរាភវោ**

**នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្ដែង វិនាសនោះឯងព្រោះហេតុដូច្នោះ

ក្ដីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទីប្រាំបីទាន់ហន់ ។

បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្ដែងឲ្យទាន

វិនាសទីប្រាំបួនអ្វីជាប្រធាន នាំសត្វឲ្យមានសេចក្ដីវិនាស ។

**សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ**

**ទុស្សតិ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

ប្រុសមិនត្រេកអរនឹងប្រពន្ធខ្លួន ហើយទៅជាប់ជួននឹងស្រីពេស្យា
ទ្រុស្តនឹងប្រពន្ធកូនជននានា ហេតុនោះទៅជានាំឲ្យវិនាស ។

**ឥតិហេតំ វិជានាម នវមោ សោ បរាភវោ**

**ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទីប្រាំបួនទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្តែងឲ្យទាន
វិនាសទីដប់អ្វីជាប្រធាន នាំសត្វឲ្យមានសេចក្តីវិនាស ។

**អតីត យោព្វនោ បោសោ អានេតិ តិម្ពរុត្ថនី**

**តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។**

បុរសមានវ័យដែលចាស់ហួសពេក ហើយមានតម្រេកដោយក្តីតណ្ហា
នាំយកស្រីក្មេងមកធ្វើភរិយា ហេតុនោះទៅជានាំឲ្យវិនាស ។

**ឥតិហេតំ វិជានាម ទសមោ សោ បរាភវោ**

**ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ វិនាសនោះឈ្មោះទីដប់ទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត សូមទ្រង់និមន្តសម្តែងឲ្យទាន
វិនាសទីដប់មួយអ្វីជាប្រធាន នាំសត្វឲ្យមានសេចក្តីវិនាស ។

**ឥត្ថឹ សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ**

**ឥស្សរិយស្មឹ ឋបេតិ**
**តំ បរាភវតោ មុខំ ។**

បុរសតាំងស្រីអ្នកលេងខ្ជះខ្ជាយ
ឬស្រីទាំងឡាយតាំងបុរសនោះ
ដែលជាអ្នកលេងខ្ជះខ្ជាយដូច្នោះ
អំពើទាំងនោះនាំឲ្យវិនាស ។

**ឥតិហេតំ វិជានាម**
**ឯកាទសមោ សោ បរាភវោ**
**ទ្វាទសមំ ភគវា ព្រូហិ**
**កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយបានដឹងជាក់ស្តែង
វិនាសនោះឯងព្រោះហេតុដូច្នោះ
ក្តីវិនាសនេះបើរាប់សង្គ្រោះ
វិនាសនោះឈ្មោះទីដប់មួយទាន់ហន់ ។
បពិត្រព្រះអង្គព្រះនាមភគវន្ត
សូមទ្រង់និមន្តសម្តែងឲ្យទាន
វិនាសទីដប់ពីរអ្វីជាប្រធាន
នាំសត្វឲ្យមានសេចក្តីវិនាស ។

**អប្បភោគោ មហាតណ្ហោ**
**ខត្តិយេ ជាយតេ កុលេ**
**សោ ច រជ្ជំ បត្ថយតិ**
**តំ បរាភវតោ មុខំ ។**

ជនណាកើតក្នុងត្រកូលជាក្សត្រ
អ្នកខ្សត់សម្បត្តិហើយប្រាថ្នាធំ
ចង់បានជាស្តេចសោយរាជស្តុកស្តម្ភ
ហេតុនោះនឹងនាំឲ្យដល់វិនាស ។

**ឯតេ បរាភវេ លោកេ**
**បណ្ឌិតោ សមវេក្ខិយ**
**អរិយោទស្សនសម្បន្នោ**
**ស លោកំ ភជតេ សិវំ ។**

ជនជាបណ្ឌិតគំនិតប្រសើរ
បានឃើញដំណើរនៃហេតុវិនាស
ដល់សត្វក្នុងលោកសន្និវាស
គេចពីវិនាសគប់រកចម្រើន ។

(ចប់ក្នុងបិដក)

# អដ្ឋកថា បរាភវសូត្រទី ៦

## “ពោលដោយសេចក្តីវិនាស ១២ យ៉ាង”

[១០] បរាភវសូត្រមានពាក្យផ្តើមថា ឯវម្មេ សុតំ (ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ) ដូច្នេះ ។

មានឧប្បត្តិហេតុដូចម្តេច? បានឮថា ទេវតាទាំងឡាយស្តាប់មង្គល-សូត្រហើយ មានបរិវិតក្កៈនេះថា “ព្រះមានព្រះភាគត្រាស់សេចក្តីចម្រើននិងសេចក្តីសួស្តីដល់សត្វទាំងឡាយក្នុងមង្គលសូត្រ ត្រាស់តែសេចក្តីចម្រើនតែម្យ៉ាងប៉ុណ្ណោះ មិនត្រាស់សេចក្តីវិនាសឡើយ ណ្ហើយចុះ ឥឡូវនេះសត្វទាំងឡាយរមែងសាបសូន្យ រមែងវិនាសដោយហេតុនៃសេចក្តីសាប-សូន្យណា ពួកយើងនឹងទូលសួរដល់នៃសេចក្តីវិនាសនោះ របស់សត្វទាំងនោះ” ។

លំដាប់នោះ ក្នុងថ្ងៃទី ២ អំពីថ្ងៃដែលត្រាស់មង្គលសូត្រ ទេវតាទាំងឡាយក្នុងម៉ឺនចក្រវាលបំណងនឹងស្តាប់ព្រះសូត្រ ពោលដោយសេចក្តីវិនាស បានប្រជុំគ្នាក្នុងចក្រវាលមួយនេះ ទើបនិម្មិតអត្តភាពតូចៗ ១០ អង្គខ្លះ ២០ អង្គខ្លះ ៣០ អង្គខ្លះ ៤០ អង្គខ្លះ ៥០ អង្គខ្លះ ៦០ អង្គខ្លះ

៧០ អង្គុលៈ ៨០ អង្គុលៈ ក្នុងឱកាសដោយហោចប៉ុនចុងរោមទ្រាយមួយ បានឈរចោមរោមព្រះដ៏មានព្រះភាគ ដែលប្រថាប់គង់លើបវរពុទ្ធាសនៈ ដែលក្រាលហើយ រុងរឿងគ្របសង្កត់ទេវតា មារ និងព្រហ្មទាំងពួង ដោយសិរី និងតេជៈ បន្ទាប់អំពីនោះ ទេវបុត្រអង្គមួយដែលសក្កទេវរាជ ជាស្តេចទេវិន្ទ:ត្រាស់បង្គាប់ហើយ ទើបទូលសួរបញ្ហាទាក់ទងជាមួយសេចក្តីវិនាសចំពោះព្រះមានព្រះភាគ លំដាប់នោះ ព្រះមានព្រះភាគទើបត្រាស់ព្រះសូត្រនេះដោយអំណាចនៃការសួរ ។

[១១] បណ្តាបទទាំងនោះ ពាក្យថា ឯវម្មេ សុតំ (ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ) ជាដើម ព្រះអានន្ទពោល ។ គាថាក្នុងលំដាប់មួយដោយន័យជាដើមថា បរាភវន្តំ បុរិសំ (បុគ្គលវិនាស) ទេវបុត្តពោល ។ គាថាក្នុងលំដាប់មួយទៀត ដោយន័យជាដើមថា សុវិជានោ ភវំ ហោតិ (អ្នកដឹងល្អ ជាអ្នកចម្រើន) និងគាថាចុងក្រោយ ព្រះមានព្រះភាគត្រាស់ ។ គាថាទាំងអស់នោះប្រមូលចូលគ្នាហើយ ហៅថា បរាភវសូត្រ ។

បណ្តាបទទាំងនោះ ក្នុងបទថា ឯវម្មេ សុតំ (ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ) ជាដើម ពាក្យណាគួរនឹងពោល ពាក្យទាំងអស់នោះខ្ញុំពោល

ទុកក្នុងអដ្ឋកថាមង្គលសូត្រហើយ ។ ចំណែកក្នុងបទមានជាដើមថា បរា-
ភវន្តំ បុរិសំ (បុគ្គលវិនាស) បានដល់ បុគ្គលវិនាស បុគ្គលសាបសូន្យ
បុគ្គលមិនចម្រើន ។ បទថា បុរិសំ (បុគ្គល) បានដល់ សត្វ គឺ អ្នក
កើតហើយណាមួយ ។

បទថា មយំ បុច្ឆាម គោតមំ (ខ្ញុំព្រះអង្គ... ទើបសូមទូលសួរ
ព្រះគោតម) សេចក្តីថា ទេវបុត្រនោះសំដែងខ្លួនព្រមទាំងទេវតាដ៏សេស
ទាំងឡាយ សូមឱកាស ទើបទូលហៅព្រះមានព្រះភាគដោយព្រះគោត្រ ។
បទថា ភគវន្តំ បុដ្ឋុមាគម្ម (មកដើម្បីនឹងទូលសួរ... ចំពោះព្រះមាន-
ព្រះភាគ) សេចក្តីថា ខ្ញុំព្រះអង្គមកអំពីចក្រវាលនោះៗ ដោយបំណងថា
នឹងទូលសួរព្រះមានព្រះភាគ ។ ទេវបុត្រសំដែងការអើពើដោយបទនេះ ។

បទថា កឹ បរាភវតោ មុខំ (អ្វីជាផ្លូវរបស់បុគ្គលវិនាស) សេចក្តី
ថា សូមព្រះអង្គទ្រង់ប្រោស ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គទាំងឡាយដែលមក
ហើយយ៉ាងនេះថា អ្វីជាផ្លូវ គឺ ជាទ្វារ ជាកំណើត ជាហេតុរបស់បុគ្គល
វិនាស ដែលនឹងធ្វើឲ្យពួកខ្ញុំព្រះអង្គគប្បីស្គាល់បុគ្គលវិនាស ។ ទេវបុត្រ
ទូលសួរហេតុនៃសេចក្តីវិនាសរបស់បុគ្គលវិនាស ដែលពោលទុកក្នុងបទ

នេះថា បាកវន្តំ បុរិសំ (បុគ្គលវិនាស) ដោយបទនេះ ។ ព្រោះកាល ជីងហេតុនៃសេចក្តីវិនាសហើយ ក៏អាចដឹងបុគ្គលវិនាសពួកខ្លះបាន ដោយហេតុសាមញ្ញនោះ ។

លំដាប់នោះ ព្រះមានព្រះភាគលុះទ្រង់សំដែងធម៌ដែលផ្ទុយគ្នា ដើម្បីទ្រង់ធ្វើឲ្យប្រាកដដោយល្អដល់ទេវបុត្រនោះ កាលទីងទ្រង់សំដែងផ្លូវនៃសេចក្តីវិនាសដោយទេសនាមានបុគ្គលាធិដ្ឋាន ទើបត្រាស់ថា សុវិជានោ ភវំ (អ្នកដឹងល្អ ជាអ្នកចម្រើន) ។

គាថានោះមានសេចក្តីថា បុគ្គលណាចម្រើន គឺ វឌ្ឍនា មិនវិនាស បុគ្គលនោះជាអ្នកដឹងបានងាយ គឺ អាចដើម្បីជ្រាបច្បាស់ដោយងាយ គឺដោយមិនលំបាក ចំណែកបុគ្គលនេះណា ជាអ្នកវិនាស ព្រោះអត្ថថា រមែងវិនាស គឺ រមែងសាបសូន្យ គឺ រមែងវិនាស ដែលពួកអ្នកសួរដល់ផ្លូវនៃសេចក្តីវិនាសរបស់បុគ្គលវិនាសនោះចំពោះតថាគត បុគ្គលនោះក៏ដឹងបានដោយងាយ ។ យ៉ាងណា? ក៏បុគ្គលនេះជាអ្នកប្រាថ្នានូវធម៌ ជាអ្នកចម្រើន គឺ រមែងប្រាថ្នា ផ្ទៀងត្រចៀកប្រាថ្នាស្តាប់ បដិបត្តិនូវធម៌ គឺ កុសលកម្មបថ ១០ បុគ្គលនោះឈ្មោះថា ជាអ្នកដឹងបានងាយ ។ ព្រោះ

ឃើញ និងស្តាប់វត្តបដិបត្តិនោះហើយ គប្បីដឹងបាន ។ អ្នកស្អប់ខ្ពើមធម៌ សូម្បីក្រៅនេះជាអ្នកវិនាស រមែងស្អប់ខ្ពើម គឺ រមែងមិនផ្ទៀងត្រចៀក មិនប្រាថ្នា មិនស្តាប់ មិនបដិបត្តិធម៌នោះឯង អ្នកស្អប់ខ្ពើមធម៌នោះ ឈ្មោះថា ជាអ្នកដឹងបានងាយ ព្រោះឃើញ និងស្តាប់វត្តបដិបត្តិខុសនោះហើយ គប្បីដឹងបាន ។

ក្នុងគាថានោះ អ្នកសិក្សាគប្បីជ្រាបយ៉ាងនេះថា ព្រះមានព្រះភាគ កាលទ្រង់សំដែងធម៌ដែលផ្ទុយគ្នាដោយអត្ថ ក៏ទ្រង់សំដែងភាពជាអ្នកប្រាថ្នាធម៌ថា ជាផ្លូវនៃសេចក្តីចម្រើន ហើយសំដែងភាពជាអ្នកស្អប់ខ្ពើមធម៌ថា ជាផ្លូវនៃសេចក្តីវិនាស ។ លំដាប់នោះ ទេវតានោះរីករាយក្រៃលែងនូវភាសិតរបស់ព្រះមានព្រះភាគ ទើបទូលថា ឥតិ ហេតំ (ព្រោះហេតុនោះឯង) ។

ខ្លឹមសារនៃពាក្យនោះថា ព្រោះហេតុនោះឯង តថាគតរមែងជ្រាបច្បាស់ គឺ រមែងកាន់យក រមែងទ្រទ្រង់ទុក នូវសេចក្តីនេះដោយប្រការដែលព្រះមានព្រះភាគត្រាស់ហើយនោះឯងថា សេចក្តីវិនាសនោះជាប្រការទី ១ គឺ សេចក្តីវិនាសនោះ មានការស្អប់ខ្ពើមធម៌ជាលក្ខណៈ ជាប្រការ

ទី ១ មានអធិប្បាយថា ពួកយើងជាអ្នកមកហើយ ដើម្បីជ្រាបនូវផ្លូវនៃសេចក្តីវិនាសពួកណា ក្នុងផ្លូវនៃសេចក្តីវិនាសទាំងនោះ នេះជាផ្លូវនៃសេចក្តីវិនាសប្រការមុន ។

ក្នុងពាក្យនោះមានវិគ្រោះថា សត្វទាំងឡាយរមែងវិនាសដោយហេតុនោះ ព្រោះដូច្នោះ ហេតុនោះទើបឈ្មោះថា បរាភវោ (សេចក្តីវិនាស) ។ សត្វទាំងឡាយ រមែងវិនាសព្រោះហេតុអ្វី? ក៏ព្រោះហេតុដែលជាផ្លូវ គឺការណ៍នៃសេចក្តីវិនាស ។ ដ្បិតថា សេចក្តីផ្សេងគ្នាក្នុងប្រការនេះ មានត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ តែដោយអត្ថ ពាក្យថា សេចក្តីវិនាស ឬថា ផ្លូវនៃសេចក្តីវិនាសមិនមានផ្សេងគ្នាឡើយ ។

ទេវបុត្រគិតថា យើងរីករាយថា យើងជ្រាបច្បាស់ផ្លូវរបស់បុគ្គលវិនាសនោះយ៉ាងនេះហើយ បំណងទីងជីងប្រការដទៃក្រៅអំពីនោះ ទើបទូលថា "បពិត្រព្រះមានព្រះភាគ សូមព្រះអង្គត្រាស់ប្រាប់បុគ្គលវិនាសទី ២ អ្វីជាផ្លូវរបស់បុគ្គលវិនាស) តអំពីនេះទៅ អ្នកសិក្សាគប្បីជ្រាបអត្ថក្នុងបទទី ៣ ទី ៤ ជាដើម ដោយន័យនោះឯង និងគប្បីជ្រាបអត្ថក្នុងចំណែកការព្យាករថា ពួកសត្វនោះៗ ប្រកបព្រមហើយដោយផ្លូវនៃសេចក្តី

វិនាសទាំងនោះៗ សត្វណាមួយមិនរួមជាមួយសត្វទាំងពួង និងសត្វទាំងពួងក៏មិនរួមនឹងសត្វណាមួយ ព្រោះដូច្នោះ ទើបទ្រង់ព្យាករដល់ផ្លូវនៃសេចក្តីវិនាសទាំងឡាយដែលផ្សេងគ្នា ដោយទេសនា មានបុគ្គលាធិដ្ឋានប៉ុណ្ណោះ ដោយន័យមានជាដើមថា "បុគ្គលមានអសប្បុរសជាទីស្រឡាញ់" ដូច្នេះ ដើម្បីទ្រង់សំដែងផ្លូវនៃសេចក្តីវិនាសនោះៗ របស់សត្វទាំងនោះ ។

ក្នុងគាថានោះ មានអត្ថវណ្ណនាដោយសង្ខេប ដូច្នេះ ៖

សាស្តាទាំង ៦ ឬបុគ្គលពួកដទៃដែលប្រកបព្រមដោយកាយកម្ម វចីកម្ម និងមនោកម្មដែលមិនស្ងប់ ឈ្មោះថា អសប្បុរស អសប្បុរសទាំងនោះជាទីស្រឡាញ់របស់បុគ្គលនោះ ដូចអចេលកកោរក្ខត្តិយៈជាដើម ជាទីស្រឡាញ់របស់មនុស្សទាំងឡាយ មានស្តេចសុនក្ខត្តៈជាដើម ។

ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវក ឬក៏បុគ្គលពួកដទៃដែលប្រកបហើយដោយកាយកម្ម វចីកម្ម មនោកម្មដ៏ស្ងប់ហើយ ឈ្មោះថា សប្បុរស ។ មិនធ្វើសប្បុរសនោះឲ្យជាទីស្រឡាញ់ ។ អធិប្បាយថា មិនធ្វើសប្បុរសនោះឲ្យជាទីស្រឡាញ់ ជាទីប្រាថ្នា ឲ្យជាទីពេញចិត្តដល់ខ្លួន ។

សេចក្តីផ្សេងគ្នានៃពាក្យក្នុងគាថានេះ គប្បីជ្រាបថា ទ្រង់ធ្វើហើយ

ដោយអំណាចនៃវេនេយ្យសត្វ ម្យ៉ាងទៀត បទថា មិនធ្វើសប្បុរសទាំងឡាយ អត្ថ ក៏គឺ មិនសេពគប់សប្បុរសទាំងឡាយ ដូចដែលលោកអ្នកដឹងសព្វទាំងឡាយពណ៌នាថា ក្នុងអត្ថនេះថា ធ្វើព្រះរាជាឲ្យជាទីស្រឡាញ់ អត្ថ ក៏គឺ រមែងសេពគប់ព្រះរាជា ។

បទថា បិយំ (ជាទីស្រឡាញ់) សេចក្ដីថា ស្រឡាញ់ ពេញចិត្ត បាមោជ្ជៈ ។ ទិដ្ឋិ ៦២ ឬអកុសលកម្មបថ ១០ ឈ្មោះថា ធម៌របស់អសប្បុរស ។ រមែងពេញចិត្ត រមែងរីករាយ រមែងប្រាថ្នា រមែងសេពក្នុងធម៌របស់សប្បុរសនោះ ។

ឋានៈ ៣ យ៉ាង គឺ ភាពជាអ្នកមានអសប្បុរសជាទីស្រឡាញ់ ១ ភាពជាអ្នកមានសប្បុរសមិនជាទីស្រឡាញ់ ១ សេចក្ដីពេញចិត្តក្នុងធម៌របស់អសប្បុរស ១ ត្រាស់ថា ជាផ្លូវនៃសេចក្ដីវិនាសដោយគាថានេះដោយប្រការដូច្នេះ ។ ក៏បុគ្គលប្រកបព្រមដោយឋានៈ ៣ យ៉ាងនោះរមែងវិនាស គឺ រមែងវិនាស រមែងមិនដល់សេចក្ដីចម្រើនក្នុងលោកនេះ ឬក្នុងលោកខាងមុខ ព្រោះដូច្នោះ ទើបហៅថា ជាផ្លូវនៃសេចក្ដីវិនាស ។ ចំណែកសេចក្ដីពិស្ដារក្នុងគាថានេះ ខ្ញុំនឹងពោលក្នុងអត្ថនៃគាថាថា ការមិន

សេពគប់បុគ្គលពាល ១ ការសេពគប់បណ្ឌិត ១ ។

បុគ្គលណាទៅក្តី អង្គុយក្តី ឈរក្តី ដេកក្តី រមែងលង់លក់នោះឯង បុគ្គលនោះ ឈ្មោះថា និទ្ទាសីលី (ពេញចិត្តដេក) ។ អ្នកតាមប្រកប សេចក្តីត្រេកអរក្នុងការស្និទ្ធស្នាល គឺ ពេញចិត្តក្នុងការនិយាយ ឈ្មោះថា សភាសីលី (ពេញចិត្តនិយាយ) ។ បទថា អនុដ្ឋាតា (មិនខ្មីឃ្មាត) បានដល់ អ្នកវៀរចាកតេជះនៃសេចក្តីព្យាយាម ជាអ្នកមិនក្រោកឡើងជាប្រក្រតី ។ ជាគ្រហស្ថត្រូវអ្នកដទៃដាស់តឿន ក៏មិនប្រារព្ធការងាររបស់គ្រហស្ថ ជា បព្វជិត ក៏មិនប្រារព្ធការងាររបស់បព្វជិត ។

បទថា អលសោ (ខ្ជិលច្រអូស) សេចក្តីថា អ្នកមានសេចក្តីខ្ជិល ច្រអូសជាម្ចាស់ ត្រូវសេចក្តីនឿកនុយគ្របសង្កត់ ឈរហើយក៏ឈរក្នុង ទីដែលឈរនោះឯង អង្គុយហើយក៏អង្គុយក្នុងទីដែលអង្គុយនោះឯង រមែង មិនសម្រេចឥរិយាបថដទៃ ដោយការឧស្សាហៈរបស់ខ្លួន ។ ក្នុងរឿងនេះ មានអតីតរឿងភ្លើងឆេះព្រៃ ក៏ខ្ជិលហើយចៀសចេញជាឧទាហរណ៍ ។ ក្នុង ទីនេះ នេះជាការកំណត់យ៉ាងឧក្រិដ្ឋ ។ ក៏សេចក្តីខ្ជិលច្រអូស សូម្បីទីង កំណត់យ៉ាងអាក្រក់ជាងនោះ ក៏គប្បីជ្រាបថា ខ្ជិលច្រអូសដូចគ្នា ។

សេចក្តីក្រោធគ្រឿងប្រាកដរបស់បុគ្គលនោះ ដូចទង់ជាគ្រឿងប្រាកដរបស់រថ ដូចផ្សែងជាគ្រឿងប្រាកដរបស់ភ្លើង ព្រោះដូច្នោះ បុគ្គលនោះទើបឈ្មោះថា កោធបញ្ញាណោ (ក្រោធងាយ) បុគ្គលដែលជាទោសចរិតក្រោធរហ័ស មានចិត្តដូចមុខដំបៅ ដូច្នោះ ។

ឋានៈ ៤ យ៉ាង គឺ ការពេញចិត្តដេក ១ និយាយច្រើន ១ មិនខ្មីឃ្មាត ១ ខ្ជិលច្រអូស ១ និងក្រោធងាយ ១ ព្រះមានព្រះភាគត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាស ដោយគាថានេះ ។ ព្រោះបុគ្គលដល់ព្រមដោយឋានៈ ៤ យ៉ាងនោះ ជាគ្រហស្ថ ក៏មិនដល់សេចក្តីចម្រើនរបស់គ្រហស្ថ ជាបព្វជិតក៏មិនដល់សេចក្តីចម្រើនរបស់បព្វជិត រមែងវិនាសនោះឯង រមែងវិនាសដោយពិត ព្រោះដូច្នោះ ទើបត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាស ។

ស្ត្រីអ្នកឲ្យកំណើត គប្បីជ្រាបថា មាតា ។ បុរសអ្នកឲ្យកំណើតនោះឯង គប្បីជ្រាបថា បិតា ។ ឈ្មោះថា បុគ្គលចាស់ជរា ព្រោះភាពជាអ្នកមានសរីរៈទ្រុឌទ្រោម ឈ្មោះថា កន្លងវ័យកំលោះទៅហើយ ព្រោះកន្លងភាពជាកំលោះក្រមុំ គឺ មានវ័យ ៨០ ឆ្នាំ ឬ ៩០ ឆ្នាំ ជាអ្នកមិនអាចធ្វើការងារទាំងឡាយដោយខ្លួនឯង ។ បទថា បហុសន្តោ (ជាអ្នក

អាច) សេចក្ដីថា ជាអ្នកអាច គឺ មានសេចក្ដីសម្រេចហើយ ជាអ្នករស់នៅយ៉ាងសប្បាយ ។ បទថា ន ភរតិ (តែមិនចិញ្ចឹម) គឺ មិនមើលថែ ។

ការមិនចិញ្ចឹម គឺ ការមិនថែរក្សា ការមិនទំនុកបំរុងមាតាបិតា ត្រាស់ថា ជាផ្លូវនៃសេចក្ដីវិនាសតែម្យ៉ាងប៉ុណ្ណោះ ដោយគាថានេះ ។ ព្រោះបុគ្គលប្រកបព្រមដោយការមិនចិញ្ចឹមមាតាបិតានោះ រមែងមិនសម្រេចអានិសង្សក្នុងការចិញ្ចឹមមាតាបិតា ដែលត្រាស់ទុកថា ៖

បណ្ឌិតទាំងឡាយរមែងសរសើរបុគ្គលនោះ ដោយការទំនុក
បំរុងនោះក្នុងមាតាបិតាក្នុងលោកនេះ គេលះលោកនេះទៅ
ហើយ រមែងរីករាយក្នុងស្ថានសួគ៌ ដូច្នេះ ។

អ្នកមិនចិញ្ចឹមមាតាបិតា រមែងបានការនិន្ទា និងការតិះដៀលថា សូម្បីមាតាបិតាក៏មិនចិញ្ចឹម គេនឹងចិញ្ចឹមបុគ្គលណាទៅហ្ន៎ និងចូលដល់ទុគ្គតិ ឈ្មោះថា រមែងវិនាសដោយពិតនោះឯង ព្រោះដូច្នោះ ទើបត្រាស់ថា ជាផ្លូវនៃសេចក្ដីវិនាស ។

បុគ្គលរមែងបញ្ឆោតនូវបុគ្គល ដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះជាអ្នកបណ្ដែតបាបទាំងឡាយហើយ ដល់អ្នកដែលបានឈ្មោះថា សមណៈ

ព្រោះជាអ្នកស្ងប់បាបហើយ ឬដល់ព្រាហ្មណ៍អ្នកកើតក្នុងត្រកូលព្រាហ្មណ៍ ដល់សមណៈអ្នកចូលដល់បព្វជ្ជា ឬដល់អ្នកសូមណាមួយសូម្បីដទៃក្រៅ អំពីនោះដោយមុសាវាទ គឺថា អ្នកបវារណាថា "បពិត្រលោកដ៏ចម្រើន លោកចូរនិយាយដល់បច្ច័យ" ត្រូវសមណៈ ឬព្រាហ្មណ៍សូមហើយ ឬថា ទទួលពាក្យហើយឲ្យតិចក្នុងកាលជាខាងក្រោយ ពោលឲ្យឃ្លៀងឃ្លាតជាមួយសមណព្រាហ្មណ៍ទាំងនោះ ។

ការបោកបញ្ឆោតព្រាហ្មណ៍ជាដើមដោយមុសាវាទ ត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាសតែម្យ៉ាងប៉ុណ្ណោះ ដោយគាថានេះ ព្រោះបុគ្គលដែលដល់ព្រមដោយការបោកបញ្ឆោតនោះ រមែងដល់នូវការនិន្ទាក្នុងលោកនេះ ដល់ទុគ្គតិក្នុងសម្បរាយភព និងវិបត្តិចាកសេចក្តីប្រាថ្នាសូម្បីក្នុងសុគតិ ។ សមដូចព្រះតម្រាស់ទុកថា "កិត្តិសព្ទដ៏អាក្រក់របស់បុគ្គលទ្រុស្តសីល អ្នកមានសីលវិបត្តិ រមែងខ្ចរខ្ចាយទៅ" មួយទៀត ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលដល់ព្រមដោយធម៌ ៤ ដូចត្រូវបោះចូលទៅក្នុងនរកដោយពិត ធម៌ ៤ នោះដូចម្តេច គឺ ជាអ្នកមានប្រក្រតីពោលកុហក" ដូច្នេះជាដើម ។ ម្យ៉ាងទៀត ទ្រង់ត្រាស់ទុកថា "ម្នាលសារីបុត្ត បុគ្គលពួកខ្លះ

ក្នុងលោកនេះ ចូលទៅរកសមណៈ ឬព្រាហ្មណ៍ហើយ ប្រាថ្នាថា បពិត្រលោកដ៏ចម្រើន សូមលោកចូរនិយាយដល់បច្ច័យ គេមិនព្រមឲ្យបច្ច័យតាមដែលបវារណា បើគេចុតិអំពីលោកនោះហើយ មកកាន់ភាពជាយ៉ាងនេះ គេប្រកបដោយការលក់ដូរណាៗ នោះ ការលក់ដូររបស់គេ រមែងដល់នូវការខាតបង់ ម្នាលសារីបុត្ត ក៏បុគ្គលពួកខ្លះក្នុងលោកនេះ ។ល។ គេរមែងឲ្យបច្ច័យតាមបវារណាទុក តាមប្រាថ្នា បើគេចុតិអំពីលោកនេះ ដល់ភាពយ៉ាងនេះ គេប្រកបដោយការលក់ដូរណាៗ ការលក់ដូររបស់គេនោះ រមែងបានកម្រៃតាមសេចក្តីប្រាថ្នា" ដូច្នេះ ។ បុគ្គលដល់នូវការទិន្នជាដើមយ៉ាងនេះ ឈ្មោះថា រមែងវិនាស ព្រោះដូច្នោះ ទ្រង់ទើបត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាស ។

បទថា បហុតវិត្តោ (មានទ្រព្យច្រើន) បានដល់ មានមាស ប្រាក់ និងកែវមណីច្រើន ។ បទថា សហិរញ្ញោ (មានមាសប្រាក់) បានដល់ មានកហាបណៈ ។ បទថា សភោជនោ (មានរបស់ស៊ី) បានដល់ ដល់ព្រមដោយរបស់ស៊ី គឺ ម្ហូបអាហារច្រើន ។ បទថា ឯកោ ភុញ្ជតិ (ស៊ី...តែម្នាក់ឯង) សេចក្តីថា មិនឲ្យរបស់ស៊ីដែលមានរសឆ្ងាញ់សូម្បីដល់បុត្ត

របស់ខ្លួន រមែងស៊ីក្នុងឱកាសស្ងាត់ ព្រោះដូច្នោះ ទើបឈ្មោះថា ស៊ីរបស់ឆ្ងាញ់តែម្នាក់ឯង ។

សេចក្តីកំណាញ់ក្នុងរបស់ស៊ី ព្រោះភាពជាអ្នកជាប់នៅក្នុងរបស់ស៊ី ត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាសតែម្យ៉ាងប៉ុណ្ណោះ ដោយគាថានេះ ព្រោះបុគ្គលដល់ព្រមដោយសេចក្តីកំណាញ់ក្នុងរបស់ស៊ីនោះ ដល់ហើយនូវហេតុទាំងឡាយមានជាដើមយ៉ាងនេះថា គឺ ការនិន្ទា ការតិះដៀល ទុគ្គតិ ឈ្មោះថា រមែងវិនាសនោះឯង ព្រោះដូច្នោះ ទើបត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាស ។

គប្បីប្រកបបទទាំងអស់តាមទំនងព្រះសូត្រ ដោយន័យតាមដែលពោលហើយនោះឯង តែឥឡូវនេះ ខ្ញុំខ្លាចទឹងពោលពិស្តារពេក ទើបមិនសំដែងន័យនៃការប្រកបសេចក្តីទាំងឡាយ និងពោលត្រឹមតែអត្ថប៉ុណ្ណោះ ។

បុគ្គលណាញុំាងមានះឲ្យកើតថា "យើងជាអ្នកដល់ព្រមដោយជាតិ" ជាអ្នកក្រៃលែងព្រោះមានះនោះ ជាបុគ្គលប៉ោងដូចស្រូបដោយខ្យល់ដូច្នោះ រមែងមិនទទន់ភ្លន់ចំពោះនរណាៗ បុគ្គលនោះឈ្មោះថា មានះព្រោះជាតិ ។ ក្នុងការមានះព្រោះទ្រព្យ និងមានះព្រោះគោត្រក៏ន័យនេះ ។ បទថា សញ្ញាតិ-

មតិមញ្ញតិ[១] (មើលងាយញាតិរបស់ខ្លួន) សេចក្តីថា រមែងមើលងាយសូម្បីញាតិរបស់ខ្លួន ព្រោះជាតិ ដូចសក្យរាជទាំងឡាយ មើលងាយដល់វិឌូឌភៈដូច្នោះ និងរមែងមើលងាយសូម្បីព្រោះទ្រព្យថា បុគ្គលនេះកំព្រាយាចក ដូច្នេះ រមែងមិនធ្វើសូម្បីត្រឹមតែសាមីចិកម្មក្នុងញាតិទាំងឡាយនោះ រមែងប្រាថ្នាសេចក្តីវិនាសប៉ុណ្ណោះ ដល់បុគ្គលនោះ ។

បាទៈមាន ៤ យ៉ាងដោយវត្ថុ មានតែមួយដោយលក្ខណៈ ត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាសដោយគាថានេះ ។

បទថា ឥត្ថីធុត្តោ (អ្នកលេងស្រី) សេចក្តីថា ជាអ្នកត្រេកអរក្នុងស្ត្រីទាំងឡាយ ឲ្យទ្រព្យដែលមានសូម្បីទាំងអស់ សង្គ្រោះស្ត្រីដទៃៗ ។ ម្យ៉ាងទៀត ជាអ្នកលះបង់របស់ដែលមានរបស់ខ្លួនសូម្បីទាំងអស់ ហើយប្រកបការផឹកស្រា ឈ្មោះថា សុរាធុត្តោ (អ្នកលេងសុរា) ។ បុគ្គលលះបង់សូម្បីសំពត់ដែលខ្លួនស្លៀកដណ្តប់ ហើយប្រកបការលេងល្បែងភ្នាល់ ឈ្មោះថា អក្ខធុត្តោ (ជាអ្នកលេងល្បែងភ្នាល់) ។ បុគ្គលដែលដល់ព្រមដោយបាទៈទាំង ៣ នោះ គប្បីជ្រាបថា បំផ្លាញទ្រព្យដែលខ្លួនរកបានមក

---

១) បដក សញ្ញាតិ អតិមញ្ញតិ ។

ព្រោះញុំាងទ្រព្យសូម្បីណាមួយដែលខ្លួនរកបានមកនោះឲ្យវិនាស បុគ្គលដូច្នេះរមែងវិនាសតែម្យ៉ាង ។ ព្រោះហេតុនោះ ឋាន: ៣ យ៉ាងនោះ ព្រះមានព្រះភាគត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាសរបស់បុគ្គលនោះ ដោយគាថានេះ ។

បទថា សេហិ ទារេហិ (ដោយកិរិយារបស់ខ្លួន) បានដល់ ដោយកិរិយារបស់ខ្លួន ។ បុគ្គលណាមិនសន្តោសក្នុងកិរិយារបស់ខ្លួន ប្រទូសក្នុងស្រីពេស្យា ឬក្នុងកិរិយារបស់អ្នកដទៃក៏ដូចគ្នា បុគ្គលនោះឈ្មោះថារមែងវិនាសតែម្យ៉ាង ព្រោះការចំណាយទ្រព្យឲ្យដល់ស្រីពេស្យា ព្រោះសេពកិរិយារបស់អ្នកដទៃ ព្រោះកម្មករណ៍មានរាជទណ្ឌជាដើម ព្រោះហេតុនោះ ឋាន: ២ យ៉ាងនោះ ទើបត្រាស់ថា "ជាផ្លូវនៃសេចក្តីវិនាសរបស់បុគ្គលនោះ" ដោយគាថានេះ ។

បទថា អតីតយោព្វនោ (បុរសចាស់) សេចក្តីថា បុរសកន្លងវ័យកំលោះ អាយុ ៨០ ឬ ៩០ ឆ្នាំហើយ នាំមក គឺ បម្រើ ។ បទថា តិម្ពរុត្ថនី (ស្ត្រីក្មេង) បានដល់ ស្ត្រីក្មេងមានដោះដូចជាផ្លែទម្លាប់ គឺ ស្រីក្មេងម្រិកម្រ៉ក់ ។ បទថា តស្សា ឥស្សា ន សុបតិ (រមែងដេកមិនលក់

ព្រោះសេចក្ដីប្រច័ណ្ឌចំពោះស្ត្រីក្មេងនោះ) សេចក្ដីថា សេចក្ដីត្រេកអរ និងការសំរាកសជាមួយបុរសចាស់ទាំងឡាយ រមែងមិនជាទីពេញចិត្តរបស់ស្រីក្មេងម្រិកម្រ៉ក់ បុរសចាស់កាលរក្សាកិរិយាក្មេងនោះ ព្រោះការប្រច័ណ្ឌថា "កុំគប្បីប្រាថ្នាបុរសកំលោះឡើយ" ឈ្មោះថា រមែងដេកមិនលក់ បុរសចាស់ត្រូវកាមរាគៈ និងសេចក្ដីប្រច័ណ្ឌដុតរោលហើយ និងមិនប្រកបការងារខាងក្រៅ ឈ្មោះថា រមែងវិនាសតែម្យ៉ាង ព្រោះហេតុនោះ ការដេកមិនលក់ព្រោះសេចក្ដីប្រច័ណ្ឌ ត្រាស់ថា "ជាផ្លូវនៃសេចក្ដីវិនាសរបស់បុរសចាស់នោះតែម្យ៉ាងប៉ុណ្ណោះ" ដោយគាថានេះ ។

បទថា សោណ្ឌឹ (ស្ត្រីអ្នកលេង) សេចក្ដីថា អ្នកឡេះឡោះ គឺជាអ្នកជាប់ចិត្តក្នុងត្រី សាច់ និងទឹកស្រវឹងជាដើម ។ បទថា វិកិរណឹ (ខ្ជះខ្ជាយ) បានដល់ អ្នកមានប្រក្រតីចាយទ្រព្យខ្ជះខ្ជាយដើម្បីប្រយោជន៍ដល់ត្រី សាច់ និងទឹកស្រវឹងជាដើម រមែងវិនាសដូចជាបាចធូលីដូច្នោះ ។ បទថា បុរិសំ វាបិ តាទិសំ (សូម្បីបុរសបែបនោះ) សេចក្ដីថា បុគ្គលណា សូម្បីតាំងបុរសនោះទុកក្នុងភាពជាធំ ឲ្យវត្ថុមានត្រាប្រថាប់ជាដើម ហើយឲ្យធ្វើសេចក្ដីខ្វល់ខ្វាយក្នុងឃរាវាស ក្នុងការងារ ឬក្នុងវោហារមាន

ការលក់ដូរជាដើម បុគ្គលនោះកាលដល់នូវការអស់ទ្រព្យ ព្រោះទោសនៃបុរសនោះ ឈ្មោះថា រមែងវិនាសតែម្យ៉ាង ព្រោះហេតុនោះ ការតាំងស្ត្រីឬបុរសបែបនោះទុកក្នុងភាពជាធំ ត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាសតែម្យ៉ាងរបស់បុគ្គលនោះ ដោយគាថានេះ ។

ឈ្មោះថា អប្បភោគោ (មានភោគ:តិច) ព្រោះមិនមានភោគទ្រព្យទាំងឡាយដែលសន្សំទុក និងព្រោះមិនមានសេចក្តីចម្រើននៃភោគទ្រព្យ ។ បទថា មហាតណ្ហោ (មានសេចក្តីប្រាថ្នាធំ) សេចក្តីថា អ្នកដល់ព្រមហើយដោយការប្រាថ្នាធំក្នុងភោគទ្រព្យច្រើន គឺ មិនសន្តោសក្នុងភោគទ្រព្យតាមដែលខ្លួនរកបានមក ។ បទថា ខត្តិយេ ជាយតេ កុលេ (កើតក្នុងត្រកូលក្សត្រ) សេចក្តីថា កើតក្នុងត្រកូលរបស់ក្សត្រ ។ បទថា សោ ច រជ្ជំ បត្ថយតិ (បុគ្គល... ប្រាថ្នារាជសម្បត្តិ) សេចក្តីថា បុគ្គលនោះប្រាថ្នារាជទាយាទដែលខ្លួនមិនគួរបាន ឬរបស់បុគ្គលដទៃ ព្រោះភាពជាអ្នកប្រាថ្នាក្នុងការប្រាថ្នារាជសម្បត្តិ គឺ ព្រោះសេចក្តីប្រាថ្នាធំនោះ ដោយមិនមែនឧបាយ គឺ ដោយខុសលំដាប់ ។ បុគ្គលនោះកាលប្រាថ្នាយ៉ាងនោះ ឲ្យភោគទ្រព្យតិចនោះដល់ជនទាំងឡាយ មានទាហានជាដើម កាលមិនសម្រេច

ផល់រាជសម្បត្តិ ឈ្មោះថា រមែងវិនាសតែម្យ៉ាង ព្រោះហេតុនោះ ការប្រាថ្នារាជសម្បត្តិនោះ ទើបត្រាស់ថា ជាផ្លូវនៃសេចក្តីវិនាសរបស់បុគ្គលនោះតែម្យ៉ាងប៉ុណ្ណោះ ដោយគាថានោះ ។

ខាងមុខអំពីនោះ ប្រសិនបើ ទេវតានោះនឹងគប្បីទូលសួរថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់ត្រាស់ប្រាប់បុគ្គលវិនាសទី ១៣ ។ល។ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គត្រាស់ប្រាប់បុគ្គលវិនាសទី ១០០.០០០ ដូច្នេះសោត ព្រះមានព្រះភាគ ក៏គប្បីត្រាស់ប្រាប់បុគ្គលវិនាសសូម្បីទាំងនោះ តែព្រោះទេវតានោះគិតថា នឹងមានប្រយោជន៍អ្វីដោយបុគ្គលវិនាសទាំងនេះដែលទូលសួរហើយ ការធ្វើសេចក្តីចម្រើនសូម្បីមួយក្នុងសូត្រនេះក៏មិនមាន ដូច្នេះ កាលមិនពេញចិត្តស្តាប់ផ្លូវនៃសេចក្តីវិនាសទាំងនោះ ទូលសួរសូម្បីត្រឹមតែប៉ុណ្ណោះហើយ ក៏វិប្បដិសារៈស្ងៀម ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ជ្រាបអធ្យាស្រ័យរបស់ទេវតានោះហើយ កាលនឹងទ្រង់ប្រមូលទេសនា ទើបត្រាស់ព្រះគាថានេះថា ឯតេ បរាភវេ លោកេ (បុគ្គលទាំងនេះជាបុគ្គលវិនាសក្នុងលោក) ។ ក្នុងបទទាំងនោះ ពាក្យថា បណ្ឌិតោ (បណ្ឌិត) បានដល់ អ្នកដល់ព្រមដោយការពិចារណាគ្រប់សព្វ ។

បទថា សមវេក្ខិយ (ពិចារណាឃើញ) បានដល់ ពិចារណាហើយដោយបញ្ញាចក្ខុ ។ បទថា អរិយោ (ប្រសើរ) បានដល់ មិនមែនដោយមគ្គ មិនមែនដោយផល តែថា ឈ្មោះថា ប្រសើរ ព្រោះអត្ថថា មិនដំណើរទៅក្នុងវត្ថុដែលមិនគួរដំណើរទៅ ពោលគឺ សេចក្តីវិនាសនោះ ។ បណ្ឌិតឃើញបុគ្គលវិនាសទាំងឡាយហើយ វៀរចាកដោយទស្សនៈណា និងដោយបញ្ញាណា ឈ្មោះថា អ្នកដល់ព្រមដោយការឃើញ ព្រោះជាអ្នកដល់ព្រមហើយដោយទស្សនៈ និងបញ្ញានោះ ។

បទថា ស លោកំ ភជតេ សិវំ (លោករមែងគប់រកលោកដែលក្សេម) បានដល់ បណ្ឌិតនោះ គឺ អ្នកឃើញបែបនោះ រមែងសេពគប់ គឺ រមែងចូលទៅជិត អធិប្បាយថា រមែងចូលទៅកាន់លោកដ៏ក្សេម គឺ ទេវលោកដែលជាឧត្តមខេត្ត មិនមានឧបទ្រវៈ ។

ក្នុងវេលាចប់ទេសនា ទេវតាទាំងឡាយស្តាប់ផ្លូវនៃសេចក្តីវិនាសទាំងឡាយហើយ ក៏តាំងចិត្តទុកដោយឧបាយ សមគួរដល់សេចក្តីសង្វេគដែលកើតឡើង សម្រេចសោតាបត្តិផល សកទាគាមិផល និងអនាគាមិផលផុតអំពីការគណនាបាន ដូចព្រះតម្រាស់ទុកថា ៖

ទេវតាទាំងឡាយដែលសម្រេចមគ្គផលក្នុងសូត្រនេះ គឺ មហាសមយសូត្រ មង្គលសូត្រ សមចិត្តសូត្រ រាហុលោវាទសូត្រ ធម្មចក្កសូត្រ បរាភវសូត្រ និងទេវតាសមសូត្រ មិនមែនតិចប្រមាណមិនបាន ក៏ធម្មាភិសម័យក្នុងបរាភវសូត្រនេះ សម្រេចមិនអាចគណនាបាន ។

ចប់អដ្ឋកថា បរាភវសូត្រទី ៦